THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០២៣

ជូនចំពោះ មាតាបិតា ក្រុមគ្រួសារ និងសិស្សដែលបញ្ចប់ការសិក្សាឆ្នាំ ២០២៣ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ដូចដែលខ្ញុំបានគិតអំពីឆ្នាំសិក្សា ២០២២-២០២៣ ដែលជាឆ្នាំដំបូងរបស់ខ្ញុំក្នុងនាមជាអគ្គនាយកក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ខ្ញុំមានមោទនភាពចំពោះអ្វីៗទាំងអស់ដែលយើងសម្រេចបានរួមគ្នា។ ឆ្នាំនេះ ក្រសួងអប់រំបានសហការជាមួយសិស្សានុសិស្ស និងក្រុមគ្រួសារដើម្បីបង្កើតផែនការយុទ្ធសាស្ត្រថ្មី *Accelerate Philly* ដែលជាផែនការដ៏សំខាន់របស់យើងសម្រាប់បម្រើសិស្ស បុគ្គលិក និងសហគមន៍ ក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។

បន្ទាប់ពីអ្វីៗទាំងអស់នោះ ស្ទើរតែមិនជឿថារដូវកាលបញ្ចប់ការសិក្សាបានខិតមកដល់សម្រាប់យើង។ និយាយឱ្យចំទៅ ខ្ញុំពិតជារំភើបចិត្តសម្រាប់សិស្សដែលបញ្ចប់ការសិក្សានៅឆ្នាំ ២០២៣ នេះ។ នៅពេលដែលខ្ញុំបានចុះទៅតាមសាលាក្នុងកំឡុងឆ្នាំសិក្សា ខ្ញុំបាន និងបន្តការបណ្ដុះគំនិតដោយរឿងរ៉ាវដែលសិស្សវិទ្យាល័យឆ្នាំទីបួនបានចែករំលែក និងការរំពឹងទុកខ្ពស់ដែលពួកគេបានកំណត់សម្រាប់ខ្ញុំ ជាអគ្គនាយកក្រសួងអប់រំ និងក្រសួងអប់រំទាំងមូល។ ការរំពឹងទុកខ្ពស់ទាំងនេះនឹងជះឥទ្ធិពលទៅលើអនាគតរបស់ក្រសួងអប់រំ និងទីក្រុងរបស់យើងទាំងមូល។

តាមការពិត សិស្សដែលបញ្ចប់ការសិក្សាឆ្នាំ ២០២៣ គួរជាទីចាប់អារម្មណ៍។ ពួកគេគឺជាសិស្សដំបូងបង្អស់ដែលបំពេញបានតាមតម្រូវការនៃការបញ្ចប់ការសិក្សាថ្មីរបស់រដ្ឋផិនស៊ីលវេនញ៉ា។ ថ្វីត្បិតតែមានការប្រឈមនឹងតម្រូវការថ្មីក៏ដោយ គិតត្រឹមថ្ងៃទី ២ ខែ មិថុនា សិស្សចំនួន ៨៨% រៀនបានមុខវិជ្ជាទៅកាន់ការបញ្ចប់ការសិក្សា។ លើសពីនេះទៀត៖

- សិស្សវិទ្យាល័យឆ្នាំទីបួនចំនួន ២០៣ នាក់ ដែលបានបញ្ចប់ការសិក្សា ត្រូវបានចុះឈ្មោះក្នុងកម្មវិធី រៀនយកមុខវិជ្ជាសម្រាប់មហាវិទ្យាល័យ (International Baccalaureate)
- សិស្សវិទ្យាល័យឆ្នាំទីបួនចំនួន ១.២០០ នាក់ ដែលបានបញ្ចប់ការសិក្សាត្រូវបានចុះឈ្មោះក្នុងកម្មវិធីសិក្សាសម្រាប់រៀនយកពិន្ទុបានពីរកន្លែង សម្រាប់ថ្នាក់ឧត្តមសិក្សា
- សិស្សវិទ្យាល័យឆ្នាំទីបួនចំនួន ១.៦៧២ នាក់ នឹងបញ្ចប់ការសិក្សា ជាមួយនឹងវិញ្ញាបនប័ត្រផ្នែកអាជីព និងបច្ចេកទេស ដែលអាចឱ្យពួកគេចូលបម្រើការងារដែលបានប្រាក់ខែថ្លៃ
- **សិស្សដែលបានបញ្ចប់ការសិក្សាឆ្នាំ ២០២៣ បានទទួលអាហារូបករណ៍ជិត ២០០ លាន ដុល្លារ!**

***សូមអបអរសាទរចំពោះការធ្វើបានល្អបំផុតដល់សិស្សដែលបញ្ចប់ការសិក្សាឆ្នាំ ២០២៣ នេះ*** - អ្នកទទួលបាននូវការសប្បាយរីករាយ និងការគោរព! សម្រាប់សិស្សមួយចំនួន ដំណើរទៅកាន់ការបញ្ចប់ការសិក្សារួមបញ្ចូលទាំងបញ្ហាដែលត្រូវប្រឈមជាច្រើន និងទុក្ខលំបាកផ្សេងៗ។ ប៉ុន្តែការខិតខំប្រឹងប្រែង ការតស៊ូ និងការតាំងចិត្តរបស់អ្នកធ្វើឱ្យអ្នកសម្រេចបាន។ អ្នកធ្វើឱ្យឧបសគ្គក្នុងជីវិត និងការសិក្សាយ៉ាងម៉ត់ចត់មានតុល្យភាព ដើម្បីបំពេញតាមតម្រូវការសិក្សាទៅកាន់ផ្លូវបញ្ចប់ការសិក្សារបស់អ្នក។ អ្នកបានបញ្ចប់ការសិក្សាពីវិទ្យាល័យ ហើយទទួលបានសញ្ញាប័ត្ររបស់អ្នក ដែលជាស្នាដៃដ៏អស្ចារ្យ!

ក្នុងរយៈពេលប៉ុន្មានខែ និងឆ្នាំខាងមុខ សិស្សមួយចំនួននឹងចូលបម្រើការងារ ឬយោធា ខណៈដែលសិស្សផ្សេងទៀតនឹងបន្តការសិក្សារបស់ពួកគេ។ ដោយមិនគិតពីផ្លូវដែលអ្នកជ្រើសរើស ខ្ញុំសុំឱ្យអ្នកធ្វើតាមសុបិនរបស់អ្នក។ ធ្វើតាមចំណង់ចំណូលចិត្ត និងគោលបំណងរបស់អ្នក។ ត្រូវមានភាពឆ្លាតវាងវៃ និងភាពក្លាហាន។ អ្នកគឺជាអ្នកនិពន្ធរឿងរបស់អ្នក - ចូរធ្វើឱ្យក្លាយជាជោគជ័យ!

ក្នុងភាពជាដៃគូ

Tony

Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា